អតិថិជនជាដៃគូរីករាយក្នុងការចាប់យក “MICE” នៅ BOREI ANGKOR RESORT & SPA

តើអ្នកអាចគិតដល់អ្វីមុនគេនៅពេលដែលយើងនិយាយទៅដល់ MICE? ប្រហែលជាអ្នកកំពុងតែស្រមៃឃើញរូបភាពសត្វកណ្តុរដ៏តូចមួយដែលត្រូវឆ្មាឬឆ្កែកំពុងដេញសង្គ្រប់ ត្រូវទេ?

តាមពិតទៅ MICE ជាផ្នែកការងារមួយយ៉ាងសំខាន់ របស់ក្រុមហ៊ុន ក្នុងការរកប្រាក់ចំណូល ហើយក៏ជាផ្នែកមួយរបស់នាយកដ្ឋានផ្នែកលក់ និងទីផ្សារ ដែលផ្នែកនេះទទួលខុសត្រូវក្នុងការរៀបចំការប្រជុំ សន្និសិទ្ធ និងពិព័រណ៍ជាដើម។

ជាមួយនឹងសេវាកម្ម ប្រកបដោយគុណភាពដែលផ្តល់ជូន ដោយក្រុមការងារដែលពោរពេញទៅដោយវិជ្ជាជីវៈ សណ្ឋាគារ Borei Angkor Resort & Spa ត្រូវបានជ្រើសរើសជាសណ្ឋាគារឈានមុខគេ ខាងផ្នែករៀបចំរាល់កម្មវិធី និងការប្រជុំផ្សេងៗ។ ជាពិសេសទៅទៀត យើងទើបតែទទួលបានលិខិតសរសើរពីលោកសាស្ត្រាចារ្យ Vincent Craig មកពីសាកលវិទ្យាល័យជាតិ អូស្ត្រាលី និងគូស្វាមីភរិយាថ្មី លោក Geoffrey និង លោកស្រី Julie McGregor អញ្ជើញមកពីប្រទេស ញ៉ូវហ្ស៊ីឡេន ចំពោះស្នាដៃក្នុងការរៀបចំកម្មវិធី ដែលបានផ្តល់ជូនដោយក្រុមការងាររបស់សណ្ឋាគារយើង។ យើងសង្ឃឹមយ៉ាងមុតមាំថា នឹងមានលិខិតសរសើរជាច្រើនទៀត នឹងមកដល់ក្នុងពេលឆាប់ៗ។

CORPORATE CLIENTS ENJOY CATCHING “MICE” AT BOREI ANGKOR RESORT & SPA

What pops up in your head when the first time you hear people say “MICE”? Perhaps you may picture small animals being chased by a cat or a dog, right?

Well, the fact is, MICE is one of backbone functions of the company to drive secondary revenue stream and is part of Sales & Marketing Department to arrange for Meetings, Incentives, Conferences, and Exhibitions.

With the service quality provided by our professional event management team, Borei Angkor Resort & Spa has been chosen as the leading meeting and event planner and we recently received a number of appreciation letters from Professor Vincent Craig from Australian National University and Geoffrey & Julie McGregor, a very happy newlywed couple from New Zealand. More appriciation to come!

ភ្ញៀវដឹងពីដំណើរប្រព្រឹត្តទៅនៃ ព្រះរាជពិធីបុណ្យ អុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក

នាយប់មួយនៅខែវិច្ឆិកា ឆ្នាំ២០១៥ វាជារាត្រីដ៏សែនមនោរម្យ និងមានអត្ថន័យបំផុតដែលសណ្ឋាគារ Borei Angkor Resort & Spa និង សណ្ឋាគារ Lotus Blanc Resort គឺជាសណ្ឋាគារដំបូងគេ ដែលបានអញ្ជើញភ្ញៀវទាំងអស់មកចូលរួមប្រារព្ធពិធីបុណ្យសំពះព្រះខែ ក្នុងយប់ទីពីរនៃ**ព្រះរាជពិធីបុណ្យ អុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក** ក្នុងគោលបំណងដើម្បីអោយភ្ញៀវបរទេសទាំងអស់ អាចទទួលបាននូវបទពិសោធន៍នៃវប្បធម៌ដ៏ថ្កុំថ្កានរបស់កម្ពុជាយើង។

វាក៏ជាឆ្នាំទីពីរហើយដែរ ដែលសណ្ឋាគារបានចូលរួមឧបត្ថម្ភ ទូកងចំនួន២ ក៏ដូចជាការបណ្តែតប្រទីតរបស់សណ្ឋាគារ Borei Angkor Resort & Spa ផ្ទាល់ នៅតាមបណ្តោយស្ទឹងសៀមរាប។

GUESTS KNOW HOW

THE CAMBODIAN'S WATER FESTIVAL IS CELEBRATED

In November 2015, there was such a meaningful night that Borei Angkor Resort& Spa and Lotus Blanc Resort were the only first hotels in Cambodia to invite guests to enrich a cultural experience of how it was like to celebrate the Cambodia's cultural moon salutation during the second day of Cambodian's Water Festival.

It was also spectacularly our second year that we took part in sponsoring two male and female racing boats as well as branding our illuminated float of Borei Angkor Resort & Spa over Siem Reap river.

INNOTALITY
បង្កើតបរិយាកាសការងារ
ជួយដល់បរិស្ថាន

Innotality មានគោលបំណងដើម្បីវាយតម្លៃលើផលប៉ះពាល់បរិស្ថាន ទាំងក្នុងកំឡុងពេលធ្វើដំណើររបស់ភ្ញៀវទេសចរណ៍ និងការអនុវត្តការងារប្រចាំថ្ងៃរបស់បុគ្គលិកយើង រួមមានដំណាក់កាលធ្វើផែនការ និងការរៀបចំផ្សេងៗដើម្បីធានាថាផលប៉ះពាល់អវិជ្ជមាន ត្រូវបានកាត់បន្ថយដល់កម្រិតអប្បបរមា។

ក្រុមសិក្សាទីផ្សារ និងផែនការណ៍កម្ម (Insight and Planning) របស់យើង បានបង្កើតឱ្យមានការអនុម័ត ដែលធ្វើឡើងនៅលើបណ្តាញអ៊ីនត្រាណិត ដើម្បីកាត់បន្ថយការអនុម័តដោយប្រើ

ក្រដាស់។ ចំពោះក្រដាស់ដែលបានចោះពុម្ពតែម្ខាង នឹងត្រូវបានយកមកប្រើប្រាស់ម្តងទៀត។ ដំណើរការ e-approval បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការកាត់បន្ថយចំនួនក្រដាសដែលត្រូវយកមកប្រើនៅក្នុងក្រុមហ៊ុនទាំងមូល។

INNOTALITY ESTABLISHES A GREENER WORKING ENVIRONMENT



INNOTALITY
Siem Reap, Kingdom of Cambodia

INNOTALITY

PURCHASE REQUISITION

No: PRN011459

Department: Offline Marketing
Requested Date: 11 Apr 2016

Required Date: 12 Apr 2016

Budget Code	Description	Model No.	Quantity On Hand	Quantity Ordered	UOM	Estimated Unit Price($)	Total Price	Is Approved	Item Requested Status	Remarks
BD001	Buy Photo For Used In Poster Promotion		0.00	1.00	pcs	$7.00	$7.00	☑	is required	Buy photo from ...
Total			0.00	1.00			$7.00			

Reference Document:

Reviewed by:	Checked by:	Verified by:	Approved by:	Final Approved by:
Status (Done)	Status (Done)	Status (Done)	Status (Done)	Status (Done)
Sam Ath Chhoeum 11/04/16 10:39	Heng Vong 11/04/16 12:05	Mengphat Ly 12/04/16 09:08	Vibol Somneas 12/04/16 19:37	Vibol Somneas 12/04/16 19:37

Innotality aims to assess environmental impacts throughout the lifecycle of tourists and our employees' establishments and operations including the planning and design phase to ensure that negative impacts are reduced to the minimum while maximising positive ones.

Our Insight and Planning team has created Online Approval on Intranet to minimize our booking form printings and use one-side printed papers for recycling printing. The e-approval process has played a very crucial role to cut down the number of papers used for such forms throughout the entire company.

INNOTALITY ដាក់ឱ្យដំណើរការ ប្រព័ន្ធគ្រប់គ្រងការដឹកជញ្ជូនលើបណ្តាញអ៊ីនធីណេត

ក្រុមការងាររបស់យើងថ្មីៗនេះ បានចាប់ផ្តើមដំណើរការ **ប្រព័ន្ធគ្រប់គ្រងការដឹកជញ្ជូន** (Fleet Management) សម្រាប់ក្រុមការងារដឹកជញ្ជូនភ្ញៀវ ដើម្បីកាត់បន្ថយភាពស្មុគស្មាញនៃការងារ និងធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិការណ៍ នៃការគ្រប់គ្រងរថយន្ត និងអ្នកបើកបរ ឱ្យកាន់តែមានប្រសិទ្ធិភាព។
នេះជាសមិទ្ធិផលថ្មីមួយទៀតដែលក្រុមសិក្សាទីផ្សារ និងផែនការណ៍កម្មរបស់យើង បានសហការជាមួយនឹងក្រុមដឹកជញ្ជូនភ្ញៀវ ដើម្បីបង្កើតនូវប្រព័ន្ធគ្រប់គ្រងការដឹកជញ្ជូននៅលើបណ្តាញអ៊ីនធីណេត ដែលជួយផ្តល់នូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធិ-ភាព និងទាន់ពេលវេលាសំរាប់ការប្រតិបត្តិការណ៍ប្រចាំថ្ងៃរបស់ក្រុមដឹកជញ្ជូនភ្ញៀវរបស់យើង។



INNOTALITY LAUNCHES NEW PRODUCT OF ONLINE FLEET MANAGEMENT

The team recently has launched the **Fleet Management system** for our concierge at Hospitality Desks to minimize the current job complexity and improve the operations flow of managing cars and drivers more effectively and efficiently. It is another milestone of remarkable achievement that our Insight and Planning team has been working with concierge team to develop the online fleet arrangement system, which help to provide a timely and efficient management of our daily concierge operation.

វត្តមាន MUDITA SPA នៅឯកម្មវិធី រត់ប្រណាំងពាក់កណ្តាលម៉ារ៉ាតុងអង្គរវត្ត

នេះជាឆ្នាំដំបូងហើយដែល Mudita Spa បានចូលរួមក្នុងកម្មវិធី **ការរត់ប្រណាំងពាក់កណ្តាលម៉ារ៉ាតុងអន្តរជាតិ លើកទី ២០** នៅប្រាសាទអង្គរវត្តកាលពីថ្ងៃអាទិត្យ ទី៦ ខែធ្នូ ឆ្នាំ២០១៥ ដោយធ្វើការរៀបស្តង់ស្ព៉ារបស់យើងក្នុង ការផ្តល់ជូននូវការម៉ាស្សាដោយឥតគិតថ្លៃដល់អត្តពលិកជាតិ និងអន្តរជាតិទាំងអស់។

ស្របពេលនឹងការផ្តល់ជូនសេវានេះ យើងក៏បានផ្តល់ជូននូវកាត **បញ្ចុះតំលៃ ២៥%** ទៅលើការម៉ាស្សា ឬការសម្រួលសរសៃគ្រប់ប្រភេទនៅ Mudita Spa ក្នុងសណ្ឋាគារ Borei Angkor Resort & Spa ។

នៅក្នុងការចូលរួមឆ្នាំដំបូងនេះពិតជាទទួលបានផ្លែផ្កា ដោយភ្ញៀវជាច្រើនដែលបានអញ្ជើញមក មានអារម្មណ៍ថាធូស្រាលច្រើន ហើយពិតជារីករាយជាមួយនឹងការផ្តល់ជូន ដោយឥតគិតថ្លៃនេះ។ គួឱ្យស្តាយ ដោយសារតែកន្លែងរបស់យើងមានកំណត់ យើងមិនអាចទទួលអត្តពលិកបានច្រើនទេ។

ក្រុមការងារទាំងអស់ ទន្ទឹងរង់ចាំដោយរីករាយ ក្នុងការចូលរួមកម្មវិធីនេះជាថ្មីម្តងទៀត គឺលើកទី២១ ក្នុងខែធ្នូ ឆ្នាំ២០១៦ ខាងមុខនេះ ហើយក៏សង្ឃឹមថានឹងអាចដាក់ស្តង់អោយកាន់តែធំជាងនេះ។

MUDITA SPA AT INTERNATIONAL ANGKOR WAT HALF MARATHON

It was the first year that the Mudita Spa joining in the 20th International Angkor Wat Half Marathon on a beautiful sunny Sunday, December 6, 2015 by setting up our branded spa booth and offering a free massage to local and international runners.

During the event, we also gave away some hundreds of 25% coupons discounted on any massage and treatment at the Mudita Spa at Borei Angkor Resort & Spa. Our first year participation was very successful as the number of visitors who came to our booth turned out very well and really enjoyed the free service we provided. Unfortunately, we could not accommodate many more runners for the massages as the space was very limited.

We look forward to joining the 21st event and make it bigger again in this upcoming December 2016.

ការទទួលបានរង្វាន់ ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ ដំបូងគេបង្អស់ពី សម្តេចនាយករដ្ឋមន្ត្រី

សណ្ឋាគារ Borei Angkor Resort & Spa មានកិត្តិយសដ៏ក្រៃលែងដែលបានទទួលនូវពានរង្វាន់ដ៏ធំចំនួនពីរគឺ **ពានរង្វាន់សុខុមាលភាពសង្គម** និង**បេតិកភ័ណ្ឌវប្បធម៌** (Social Welfare and Cultural Heritage) និង**ពានរង្វាន់សហគ្រិន** (Entrepreneur) ដែលប្រគល់ជូនដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ប្រសិនបើគ្មានការប្តេជ្ញាខិតខំប្រឹងប្រែងយ៉ាងក្លៀវក្លា ពីសំណាក់សមាជិកគ្រួសារទាំងអស់ទេ យើងក៏ប្រហែលជាមិនអាចមានមោទនភាពក្នុងនាមជាក្រុមហ៊ុនដែលឈ្នះរង្វាន់ដូចថ្ងៃនេះដែរ។

ពួកយើងនឹងព្យាយាមប្រឹងប្រែងបន្ថែមទៀត ដើម្បីទទួលបាននូវពានរង្វាន់បន្ថែមនាពេលខាងមុខ។

THE **FIRST ECO-BUSINESS AWARDS EVER**
PRESENTED BY THE **PRIME MINISTER**

Borei Angkor Resort & Spa takes pride in winning the two prestigious awards of "Social Welfare and Cultural Heritage" and "Entrepreneur" which are honorably ever initiated and presented by the Cambodian Prime Minister Samdech Akeak Moha Sena Padey Techo HUN SEN.

Without a long-committing momentum of hard work from each of our family members, we wouldn't be here so proud today of being part of the winning organization. We are even working harder in order to get more awards in the coming years.

ដៃគូ OTA នៅតែផ្តល់ ពានរង្វាន់
ជាហូរហែរដល់អាជីវកម្មទាំងឡាយរបស់ INNOTALITY

កំឡុងពេល២ត្រីមាសដំបូង នៃឆ្នាំ២០១៥ ដល់ ២០១៦នេះ Innotality មានមោទនភាព ដែលបានឈ្នះពានរង្វាន់ឆ្នើមជាច្រើន ពីដៃគូភ្នាក់ងារទេសចរណ៍ធំៗតាមបណ្តាញអ៊ីនធឺណេត ដែលបានផ្តល់ជូនដល់សណ្ឋាគារទាំងអស់របស់ Innotality ក្នុងនាមជាសណ្ឋាគារ ដែលផ្តល់សេវាកម្មបដិសណ្ឋារកិច្ចដ៏ល្អដាច់គេតាមប្រព័ន្ធអ៊ីនធឺណេត។

ពានរង្វាន់ Agoda´s Gold Circle 2015 បានទៅលើសណ្ឋាគារពីរក្នុងចំណោមសណ្ឋាគារទាំងបួនរបស់យើងគឺ Borei Angkor Resort & Spa និង Privilege Floor@Borei Angkor។

មួយទៀតពានរង្វាន់សណ្ឋាគារឆ្នើម ២០១៥ របស់ Booking .com´s Award of Excellence 2015 ក៏បានប្រគល់ជូនដល់ Privilege Floor @Lotus Blanc ក្នុងការដែលទទួលបានពិន្ទុនៃការវាយតម្លៃ ជាមធ្យមចំនួន ៩.៤ពិន្ទុ ហើយ Privilege Floor @Borei Angkor ចំនួន ៩ .៣ពិន្ទុ បន្ទាប់មក Lotus Blanc Resort ៩.២ពិន្ទុ និង Borei Angor Resort & Spa ចំនួន ៩.0ពិន្ទុ។ លើសពីនេះទៅទៀតសណ្ឋាគារ Borei Angor Resort & Spa ក៏បានឈ្នះរង្វាន់លើភាពជាដៃគូសណ្ឋាគារឆ្នើមផងដែរ។

ទន្ទឹមនឹងនេះដែរ Expedia.com ក៏បានប្រគល់ពានរង្វាន់ Token of 2015 ជូនដល់ Borei Angor Resort & Spa ក្នុងនាមជាសណ្ឋាគាររកចំណូលខ្ពស់បំផុត (Top Revenue Producer) របស់គេ និង Lotus Blanc Resort ជាសណ្ឋាគារដែលលក់បន្ទប់ពេលយប់ខ្ពស់បំផុត (Top Room Night-Producer) របស់គេ។

ហើយជាចុងក្រោយ យើងក៏ទទួលបានការទទួលស្គាល់មួយទៀតពី Hotels.com ជាមួយនឹងពិន្ទុដ៏ល្អប្រសើរនៃការវាយតម្លៃពីភ្ញៀវប្រចាំឆ្នាំ ២០១៥ គឺចំនួន ៤.៩ពិន្ទុ លើពិន្ទុសរុបចំនួន ៥ពិន្ទុ ផ្តល់ជូនដល់សណ្ឋាគារ The Privilege Floor @Borei Angkor និង ៤.៦ពិន្ទុ ផ្តល់ជូនដល់សណ្ឋាគារ Borei Angkor Resort & Spa និង Lotus Blanc Resort។

OTA PARTNERS CAN'T STOP GIVING THEIR **RECOGNITION AWARDS** TO **INNOTALITY PROPERTIES**

During the first and second quarters of 2015 -2016, Innotality takes pride in winning a number of outstanding awards from our potential online travel agent partners given to our **Innotality** properties that embody the best qualities of the online hospitality industry.

The **Agoda's Gold Circle Award 2015** goes to two out of our four properties – **Borei Angkor Resort & Spa** and **The Privilege Floor @Borei Angkor**.

On the other hand, the **Booking.com's Award of Excellence 2015** is also presented to **The Privilege Floor @Lotus Blanc** achieving an overall review **score of 9.4** and **The Privilege Floor @Borei Angkor** at **9.3** followed by **Lotus Blanc Resort** and **Borei Angkor Resort & Spa** at **9.2** and **9.0** respectively. Furthermore, **Borei Angkor Resort & Spa** also wins as the Outstanding Hotel Partner.

Meanwhile, Expedia.com eventually presents its **Token of 2015 Award to Borei Angkor Resort & Spa** as its **Top Revenue Producer** and **Lotus Blanc Resort** as its **Top Room Night Producer**.

Last but not least, we also receive another recognition from **Hotels.com** with the **2015 Outstanding Guest Review Score** of **4.9** out of 5 given to **The Privilege Floor @Borei Angkor**, and **4.6** to **Borei Angkor Resort & Spa** and **Lotus Blanc Resort**.

គេហទំព័រតស្លូ កាន់តែមាន ភាពរហ័ស និង ងាយស្រួលមើលជាងមុន

ការធ្វើអាជីវកម្មសព្វថ្ងៃនេះ វាចាំបាច់ខ្លាំងណាស់ដែលត្រូវមានគេហទំព័រ (វេបសាយ) លើប្រព័ន្ធអ៊ីនធឺណេត។ ចូរអ្នកស្រមៃមើលថាប្រសិនបើអ្នកមានសណ្ឋាគារមួយដែលគ្មានគេហទំព័រ តើវាលំបាកប៉ុណ្ណា ខណៈដែលពិភពលោកត្រូវបានគ្រប់គ្រងដោយប្រព័ន្ធអ៊ីនធឺណេត និងបច្ចេកវិទ្យាដ៏ទំនើបទៅហើយនោះ។

យើងមានក្រុមការងារផ្នែកទីផ្សារដែលមានសមត្ថភាពខ្ពស់ ក្នុងការរចនាគេហទំព័រ ដោយបានប្តូរពីទំរង់ចាស់ទៅជាទំរង់ថ្មីដែលជំណើរការកាន់តែរហ័សជាងមុន ហើយអាចបត់បែនបាននិងមើលឃើញយ៉ាងត្រជាក់ភ្នែកលើគ្រប់ឧបករណ៍ ដែលផ្តល់ភាពងាយស្រួលដល់គ្រប់ការធ្វើអាជីវកម្មរបស់ Innotality។ ថ្មីៗនេះយើងបានកែប្រែនូវគេហទំព័ររបស់ សណ្ឋាគារ Borei Angkor Resort & Spa ជាថ្មីដោយជោគជ័យហើយថែមទាំងបានដាក់ឱ្យដំណើរការ នូវគេហទំព័រថ្មីចំនួនពីរផ្សេងទៀតរបស់ **ភោជនីយដ្ឋាន** Damnak Lounge Fine Dining និង Mudita Spa ដែលអនុញ្ញាតឱ្យភ្ញៀវធ្វើការស្វែងរកដោយងាយស្រួលតាមអ៊ីនធឺណេតដូចជា Google, Yahoo, Bing ជាដើម និងធ្វើការកក់បន្ទប់ ឬសេវាកម្មផ្សេងៗដោយផ្ទាល់ តាមរយៈគេហទំព័ររបស់យើងទៀតផង។

មានគេហទំព័រមួយដ៏ល្អហើយនោះ ក្រុមការងាររយើងក៏មិនទាន់បញ្ឈប់តែត្រឹមប៉ុណ្ណឹងដែរ។ យើងនៅតែបន្តធ្វើវាឱ្យកាន់តែប្រសើរ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការស្វែងរក ងាយមើលឃើញ និងងាយស្រួលទៅដល់អតិថិជន។

WEBSITES ARE NOW **MORE RESPONSIVE & FRIENDLY** TO **HUMAN**

Running a business these days is very important to have a website. Imagine if you have a hotel without it, it's becoming difficult when the world is dominated by Internet and high technology.

We have our online marketing team who are capable of building a website that moves from traditional statics to a more responsive template across all devices for all the businesses of Innotality.

Lately, we successfully revamped a new development website of Borei Angkor



Resort & Spa and eventually launched other two new websites of Damnak Lounge Fine Dining and Mudita Spa that allow online travelers to find us through search engines (Google, Yahoo, Bing, etc.) and book us through our own websites. Having an exceptional website ready does not stop us from there, the team will technically continue to optimize it more in order to make sure that the website is more searchable, visible, and friendly to online customers.



ការចាប់ផ្តើមដំណើរការ ភោជនីយដ្ឋាន DAMNAK LOUNGE FINE DINING

ភោជនីយដ្ឋាន Damnak Lounge Fine Dining ដែលមានទីតាំងស្ថិតនៅជាន់ទីមួយក្នុងសណ្ឋាគារ Lotus Blanc Resort បានបង្កើតឡើង និងចាប់ផ្តើមដំណើរការចាប់ពីខែតុលា ឆ្នាំ២០-១៥ តទៅ។ សកម្មភាពទីផ្សារត្រូវបានផ្សព្វផ្សាយ មានដូចជាបដារ៉ឺម៉ក(ម៉ូតូកង់បី) ខិតប័ណ្ណ និងការផ្សព្វផ្សាយនៅលើសៀវភៅមគ្គុទ្ទេសខេត្តសៀមរាប ព្រមទាំងមានវត្តមាននៅលើបណ្តាញគេហទំព័រផ្ទាល់ខ្លួន ប្រព័ន្ធផ្សព្វផ្សាយសង្គម **ហ្វេសបុក** គេហទំព័រ TripAdvisor និងកាតសមាជិករបស់ Kambodia Resident Card ទៀតផង។

ជាមួយនឹងគំរោងទីផ្សារដ៏ជោគជ័យ រួមទាំងការបំរើសេវាកម្មជូនភ្ញៀវគួរជាទីគាប់ចិត្តរបស់ក្រុមការងាររបស់យើង បានធ្វើឱ្យភោជនីយដ្ឋាន Damnak Lounge Fine Dining ទទួលបានចំនាត់ថ្នាក់កំពូល នៅលើគេហទំព័រ TripAdvisor ក្នុងចំនោមភោជនីយដ្ឋានទាំងអស់ចំនួន ៥៧៧ ក្នុងខេត្តសៀមរាប។

កន្លងទៅថ្មីៗនេះ យើងក៏បានស្វាគមន៍តារាជាតិ និងអន្តរជាតិល្បីៗដូចជា តារាចម្រៀងអាមេរិច Amenda Wood និងតារាម៉ូដែលកម្ពុជា កញ្ញា **មាន សូនីតា** ហើយយើងក៏ទន្ទឹងរង់ចាំដោយក្តីរីករាយ ចំពោះការអញ្ជើ-ញមករីករាយពិសារភោជនាអាហារ របស់ភ្ញៀវកិត្តិយសទាំងឡាយ ក្នុងពេលខាងមុខនេះ។

THE LAUNCH OF "DAMNAK LOUNGE FINE DINING"

The Damnak Lounge Fine Dining located on first floor of Lotus Blanc Resort was initiated to launch its opening from October 2015 onwards. The marketing activities have been undergoing viral ranging from Remarque's (tuk-tuk) banners, leaflets, and advertisement on Siem Reap guidebook to online presence of own website, social media, TripAdvisor, and Kambodia Resident Card.

With the great success of our initiated marketing plan together coupled with the operational excellence from our F&B team, the Damnak Lounge Fine Dining is favorably chosen by our satisfied diners as the top restaurant on TripAdvisor among other 577 restaurants in Siem Reap.

So far, we also welcomed famous local and international celebrities such as American signer Amanda Wood and Cambodian model Mean Sonyta and we look forward to welcoming more visits from other distinguished guests in the near future.

សុវត្ថិភាព និយោជិត និង ភ្ញៀវ គឺជាអាទិភាពចំបងរបស់យើង

សុវត្ថិភាពនិយោជិត និងភ្ញៀវ តែងតែជាអាទិភាពចំបងរបស់យើង។ យើងមិនអាចដឹងជាមុននោះទេថា នឹងមានហេតុការណ៍អាក្រក់អ្វីនឹងកើតឡើង ប៉ុន្តែយើងអាចដឹងជាមុនថាអ្វីដែលជាដើមចម និងវិធីការពារដើម្បីបញ្ជៀសបញ្ហានោះ។ នៅក្នុងហេតុ-ការណ៍អាក្រក់មួយដែលកើតឡើយដោយចៃដន្យ ដូចជាអគ្គីភ័យជាដើម ជីវិត និងទ្រព្យសម្បត្តិត្រូវប្រឈមនឹងហានិភ័យ។ ទោះជាយ៉ាងណាក៏ដោយ ការយល់ដឹងពីរបៀបក្នុងការបង្ការមិនឱ្យរឿងនោះកើតឡើង និងអ្វីដែលត្រូវធ្វើនៅពេលដែលវាកើតឡើងនឹងជួយយើងក្នុងការកាត់បន្ថយហានិភ័យនោះ។

នៅក្នុងសាជីវកម្ម Innotality យើងបានបង្កើតបរិយាកាសប្រកបដោយសុវត្ថិភាព និងសុខុមាលភាពសំរាប់បុគ្គលិក និងភ្ញៀវដែលមកស្នាក់នៅក្នុងសណ្ឋាគាររបស់យើង។ ជាផ្នែកមួយនៃយន្តការសុវត្ថិភាពរបស់យើង យើងធ្វើឱ្យប្រាកដថាបុគ្គលិកទទួលបានការបណ្តុះបណ្តាលយ៉ាងល្អ និងរំលឹកជាទៀងទាត់នូវជំនាញពន្លត់អគ្គីភ័យដើម្បីបង្កើនចំណេះដឹង និងជំនាញរបស់ពួកគាត់ក្នុងការការពារខ្លួនឯង ភ្ញៀវ និងទ្រព្យសម្បត្តិផ្សេងៗ។ ក្នុងខែកុម្ភៈ ឆ្នាំ២០១៦ វគ្គបណ្តុះបណ្តាលមួយទៀតត្រូវបានប្រារព្ធឡើងដោយមានការចូលរួមពីបុគ្គលិកចំនួន ៥៩នាក់ ដែលក្នុងនោះក៏មានគណៈគ្រប់គ្រងផងដែរ។
សូមទៅជួបប្រធានផ្នែករបស់អ្នកប្រសិនបើអ្នកមានចម្ងល់ពីមូលហេតុដែលអាចបង្កឱ្យមានអគ្គីភ័យ និងអ្វីទៅដែលអ្នកត្រូវធ្វើនៅពេលមានអគ្គីភ័យកើតឡើង។

ចូរសង្គ្រោះខ្លួនឯង ក្រុមគ្រួសារ ផ្ទះរបស់អ្នក ភ្ញៀវរបស់យើង និងទ្រព្យសម្បត្តិរបស់ Innotality តាមរយៈការស្វែងយល់ពីវិធីពន្លត់អគ្គីភ័យ។

SAFETY OF EMPLOYEES & GUESTS IS OUR TOP PRIORITY

Safety of our employees and guests is always on top of our priority. We never know in advance when an unexpected incident will happen, but we know what cause it and how to prevent it from happening.

In the worst case of fire, lives and properties will be at risk. However, understanding how to prevent them from happening and what to do when it's on fire will help us reduce that risk.

At Innotality, we create the environment of safety and well-being for the employees and the guests working and residing inside our properties. As part of our safety mechanism, we ensure staff are well trained and regularly refreshed to enhance their knowledge and skills of firefighting to safeguarding themselves, the guests and their properties. In February 2016, another series of refreshing training was conducted with the participation from 59 employees, including our management team. Please reach out to your managers if you may have any doubt of what cause fire and what you are supposed to do in the event of fire.

Save yourself, your family, your houses, our guests and Innotality's properties from fire –learn firefighting!

អ្នកគឺជាក្រុមគ្រួសាររបស់ INNOTALITY

យើងយកចិត្តទុកដាក់ចំពោះអ្នក!

ជាមួយនឹងការសណ្តោសប្រោសប្រណីអស់ពីបេះដូង និងគតិបណ្ឌិតដ៏ជ្រាលជ្រៅពី លោកជំទាវ **គួយ ណាលីន** យើងមានកម្មវិធី "**ប្រសិទ្ធពរជ័យចំពោះការមានគភ៌**" ដល់សហការិនីរបស់យើង។ លោកជំទាវបានផ្តល់ដំបូន្មានថា "**គ្មានអ្វីអាចបរិ-យាយពីការខិតខំប្រឹងប្រែង និងការលះបង់ដែលម្តាយធ្វើចំពោះយើងបានទេ។ គ្រាន់តែនៅដំណាក់កាលមានគភ៌តែមួយគត់ម្តាយឆ្លងកាត់នូវភាពស្មុគស្មាញជាច្រើន។ ពួកគាត់ជ្រើសរើសផ្លូវមួយដែលពោរពេញទៅដោយភាពលំបាកដែលគ្មានបុរសណាម្នាក់លើលោកនេះអាចយល់ទាំងស្រុងបានទេ**"។ ហេតុដូច្នេះហើយ ជានិច្ចកាលយើងតែងតែទៅសួរសុខទុក្ខសហការិនីរបស់យើង ព្រមទាំងទារកដែលទើបចាប់កំណើត ដោយជូនពរម្តាយ និងកូនឱ្យមានសុខភាពល្អ។ កាន់តែពិសេសជាងនេះទៅទៀត ជាការអបអរសាទរ ពួកគាត់នឹងទទួលបានទឹកប្រាក់ចំនួន **១០០ ដុល្លា** និងប្រាក់ខែ **១០០%** ពេញ ក្នុងកំឡុងពេលនៃមាតុភាពរបស់គាត់។

ម្យ៉ាងវិញទៀត យើងក៏តែងតែយកចិត្តទុកដាក់ផងដែរចំពោះបុគ្គ-លិករបស់យើង នៅពេលដែលគាត់មានគ្រោះថ្នាក់ ឬឈឺ ឬប្រទះការលំបាកផ្សេងៗទៀត។ ថ្មីៗនេះយើងបានចុះសួរសុខទុក្ខបុគ្គ-លិក ដែលជួបគ្រោះថ្នាក់នៅក្នុងម៉ោងការងារ ដែលគ្រោះថ្នាក់ការងារនេះទទួលបានការធានារ៉ាប់រងពីបេឡាជាតិរបបសន្តិសុខសង្គម ទៅតាមគោលការណ៍ធានារ៉ាប់រងរបស់មូលនិធិ សន្តិសុខសង្គមជាតិបច្ចុប្បន្ន ។

យើងទាំងអស់គ្នាគឺជាគ្រួសាររបស់ Innotality។ យើងតែងយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមក ទាំងផ្នែកបុគ្គល និងផ្នែកវិជ្ជាជីវៈ។

YOU ARE
INNOTALITY'S FAMILY
WE CARE ABOUT YOU!

With the heartfelt sympathy and profound wisdom from Lok Chom Teav **Naline KUOY**, we have the "**Pregnancy Blessing**" program for our female colleagues. "Nothing can

describe the efforts and sacrifice that mothers make for us. Just at the stage of pregnancy alone, mothers experience many complications. They opt for a road filled with hardships that no men on earth can ever fully comprehend" she advises. Thus, regularly we have visited our female colleagues with their new born baby and wishing them all the best and healthiest. More than that, to congratulate them, $100 in cash and 100% of their salaries are offered during their maternity leave.

We also visit and take care our colleagues who have accidents, sicknesses and other difficulties. Recently we have visited our colleagues who got work-related accidents which is covered by National Social Security Fund (NSSF) as per the current insurance coverage policy.

We are **Innotality's family**. We care about each other in both professionally and personally.

ថ្ងៃដ៏សំខាន់របស់អ្នក ត្រូវបានចងចាំ និង យកចិត្តទុកដាក់

កន្លែងធ្វើការជួនកាលត្រូវបានចាត់ទុកថាជាផ្ទះទីពីរ ដែលអ្នកបានចំណាយពេលវេលាភាគច្រើននៅទីនេះ។ ដូចជាផ្ទះយើងអញ្ចឹងដែរ យើងចង់ឱ្យអ្នកមានអារម្មណ៍កក់ក្តៅ ទទួលបានការគោរព ស្រលាញ់រាប់អាន និងយកចិត្តទុកដាក់ ព្រោះដោយសារតែអ្នកគឺជាផ្នែកមួយនៃគ្រួសារ Innotality របស់យើង។ យើងទាំងអស់គ្នាគ្រប់ជាន់ថ្នាក់ តែងតែចងចាំជានិច្ចនូវថ្ងៃដ៏សំខាន់របស់អ្នក ពោលគឺយើងចូលរួម និងអបអរសាទរសម្រាប់ថ្ងៃខួបកំណើតរបស់អ្នក។ យើងចង់មានអនុស្សាវរីយ៍ ដែលមិនអាចបំភ្លេចបានក្នុងថ្ងៃដ៏ពិសេសនេះ ហេតុដូច្នេះហើយ យើងសម្រាកពីការងារប្រហែលជាពីរម៉ោង ដើម្បីចូលរួមរីករាយ និងលេងសប្បាយខ្លះជាមួយអ្នក។ យើងលេង យើងច្រៀងបទចម្រៀងរីករាយថ្ងៃកំណើតសម្រាប់អ្នក យើងថតរូបអនុស្សាវរីយ៍ជាមួយគ្នា ហើយបន្ទាប់មក យើងអាចទទួលទានអាហារសម្រន់ដ៏ឆ្ងាញ់ជាមួយគ្នាទៀតផង។ អ្នកប្រហែលជាពុំបានដឹងខ្លួនទេថាអ្នកមានសារៈសំខាន់ខ្លាំងប៉ុណ្ណាចំពោះគ្រួសារមួយនេះទេ។ ដូច្នេះហើយ យើងចង់ឱ្យអ្នកដឹង ថាយើងតែងតែខ្វល់ខ្វាយអំពីអ្នក ដោយមិនបែងចែកថាអ្នកជានរណា អ្នកមានតួនាទីអ្វី ឬក៏អ្នកមកពីកន្លែងណានោះឡើយ!

YOUR IMPORTANT DAY IS REMEMBERED AND CARED

The workplace, to some extent, is regarded as a second home where you spend most of your time in. Like home we want you to feel warm, respected, loved and cared since you are part of our **Innotality** family. We, the management team and all our associates, always remember your important day as we participate and celebrate for your birthday. We want to make your special day memorable; hence, we take about two hours break just to enjoy and have some fun with you. We play, we sing happy birthday song for you, we have a photo taken together with you and then we can have very delicious snacks together. You can't imagine how important you are to this family; therefore, we want to let you know that we always care about you, no matter who you are, what position you hold or where you are from!

ការបណ្តុះបណ្តាល អ្នកដឹកនាំជំនាន់ក្រោយ

"ទេពកោសល្យ" គឺជាធាតុផ្សំនៅក្នុងទិសដៅជាយុទ្ធសាស្ត្រមួយនៃទិសដៅចំម្បងនានារបស់ INNOTALITY។ គណៈគ្រប់គ្រងជឿជាក់ថា អ្នកគ្រប់គ្នានៅក្នុងក្រុមហ៊ុននេះ មានទេពកោសល្យ ហើយអ្នកខ្លះអាចនឹងមានសក្តានុពលក្លាយជាអ្នកដឹកនាំជំនាន់-ក្រោយ។ ទោះបីជាពួកគាត់បានចាប់ផ្តើមការងារក្នុងតួនាទីតូចក៏ដោយ ក៏ពួកគាត់អាចត្រូវបានបំផុសគំនិត និងអភិវឌ្ឍន៍បន្តិចម្តងៗ ដើម្បីអាចកាន់កាប់តួនាទីធំបានដែរ។ វាក៏មានន័យដែលថាថ្នាក់ដឹកនាំជឿជាក់ លើសមត្ថភាពរបស់និយោជិតខ្មែរយើង ហើយក៏មានជំនឿផងដែរថា អ្នកដឹកនាំត្រូវការបណ្តុះបណ្តាលមិនមែនចេះដឹកនាំពីកំណើតនោះទេ។

ទន្ទឹមនឹងអាជីវកម្មកំពុងមានការរីកចំរើន យើងត្រូវការអ្នកដឹកនាំដែលមានសមត្ថភាព និងភ្ជៀវភ្លា។ ដោយមានជម្រើសបែបនេះ ហើយទើប Innotality ត្រូវប្រាកដថាក្រុមការងារនៅក្នុងក្រុម-ហ៊ុននឹងត្រូវបណ្តុះបណ្តាលយ៉ាងល្អ ដើម្បីទទួលខុសត្រូវនៅក្នុងតួនាទីខ្ពស់ជាងនេះនៅពេលមានតំណែងទំនេរ ឬឱកាសហុចឱ្យ។ ឆ្លើយតបនឹងផ្នត់គំនិត និងជំនឿខាងលើ យើងបានណែនាំកម្មវិធីមួយដែលមានឈ្មោះថា " **អ្នកដឹកនាំជំនាន់ក្រោយ** " ។ កម្មវិធីនេះមានគោលបំណងដើម្បីអភិវឌ្ឍន៍អ្នកដែលមានតួនាទីសំខាន់ៗមួយចំនួន ដោយប្រើរយៈពេលខ្លីដើម្បីឱ្យគាត់ត្រៀមខ្លួនជាស្រេច សំរាប់កាន់កិច្ចការដែលខ្ពស់ជាងនេះ ក្នុងរយៈពេលមួយឆ្នាំកន្លះ ឬពីរឆ្នាំទៀត។ សម្រាប់វគ្គដំបូង បេក្ខជនចំនួន ២១នាក់ ត្រូវបានចាត់តាំងចូលក្នុងកម្មវិធីនេះ ដែលពួកគាត់ត្រូវឆ្លងកាត់ដំណាក់កាលនៃការជ្រើសរើស មុនពេលទទួលបានការបណ្តុះបណ្តាល ដើម្បីត្រៀមខ្លួនសំរាប់កាន់តួនាទីជាអ្នកដឹកនាំនាពេលអនាគត។ កម្មវិធីនេះនឹងធ្វើឡើងជាបន្តបន្ទាប់ហើយអ្នកគ្រប់គ្នាដែលមានតួនា-ទីសំខាន់ៗ នឹងនៅតែមានឱកាសក្នុងការចូលរួមនៅវគ្គបន្ទាប់ៗទៀត។

DEVELOPING THE NEXT GENERATION OF LEADERS

"Talent" is a component in one of our Innotality Strategic Imperatives. The management team believe that everyone in the company has talent and some will potentially be next generation of leaders. Even though they start small, they can eventually be inspired and developed to become bigger. That also means they believe in the capacity of our local talents and that the leaders are made, not born.

While the business is growing at a fast speed, strong and enthusiastic leaders are needed. As this is a given choice, Innotality has the opportunity to ensure the internal team will be well developed to take charge in the higher role when a vacancy or time arrives. In response to the above mindset and belief, we introduced a program called "Next Generation Leader". The program aims to fast-track and develop those in key positions to be ready in the higher positions in the next one and a half or two years. For the first batch, 21 candidates were nominated for the program and will need to go through a selection process before being developed to be ready in the future leader role. It is an on-going process; everyone in the key positions will stand a chance to participate.

ការអភិវឌ្ឍន៍អាជីពនៅ INNOTALITY

Innotality ផ្តល់ឱកាសស្មើភាពគ្នា សម្រាប់អ្នកដែលមានទេពកោសល្យ ក្នុងការរីកលូតលាស់នៅក្នុងក្រុមហ៊ុន។ គណៈគ្រប់គ្រងជឿនិងទុកចិត្តលើទេពកោសល្យ របស់បុគ្គលិកកម្ពុជារបស់យើងថាពួកគាត់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងារក្នុងកំរិណងដែលខ្លួនកំពុងធ្វើ ឬក៏ខ្ពស់ជាងនេះ និងមានសក្តានុពលដើម្បីឆ្ពោះទៅមុខ។

និយោជិតនឹងត្រូវគេពិចារណាតំឡើងតំណែង ប្រសិនបើគាត់អាចសំរេចការងារបានយ៉ាងល្អជាប់ៗគ្នាពីមួយឆ្នាំទៅមួយឆ្នាំ មានសមត្ថភាពក្នុងការចាប់យកអ្វីដែលថ្មីបានយ៉ាងលឿន អាចសំរបខ្លួនទៅនឹងការផ្លាស់ប្តូរ និងដោះស្រាយបញ្ហាប្រឈម ប្រកបដោយប្រសិទ្ធភាព។ ជាមួយគ្នាផងដែរ ពួកគាត់មានចំណង់ក្នុងការឈានឆ្ពោះទៅមុខ មានអារម្មណ៍ក្នុងការចូលរួម និងមានសុទិដ្ឋិនិយមអំពីអនាគតរបស់ក្រុមហ៊ុន។ សំខាន់ជាងនេះទៅទៀតគឺពួកគាត់មានភាពស្មោះត្រង់ និងមានភក្តីភាពចំពោះក្រុមហ៊ុន។

នៅប៉ុន្មានឆ្នាំចុងក្រោយនេះ បុគ្គលិកជាច្រើនបានអភិវឌ្ឍអាជីពរបស់ខ្លួននៅក្នុង Innotality។ អ្នកទាំងនោះមានដូចជា៖

កញ្ញា ភឿន ប៊ុណ្ណា បានអភិវឌ្ឍអាជីពរបស់គាត់ពី ជំនួយការប្រធានផ្នែកបដិសណ្ឋារកិច្ច ទៅជា អ្នកគ្រប់គ្រងផ្នែកបទពិសោធន៍ទូទៅ។

Ms. Phoeun Bunna has advanced her career from Assistant Resident Host Manager to Head of Experience.

លោក ហ៊ាប ដានេត ពីប្រធានផ្នែកលទ្ធកម្ម ទៅជាអ្នកគ្រប់គ្រងផ្នែកលទ្ធកម្ម។

Mr. Heap Daneth, from Procurement Manager to Head of Procurement.

នៅមានឈ្មោះជាច្រើនទៀតដែលយើងរៀបរាប់មិនអស់។

CAREER ADVANCEMENT AT INNOTALITY

Innotality provides a fair opportunity for talented people to grow in the company. The management team believes and trusts our Cambodian talents that they are competent enough to perform at their level or higher and that they have potential to move forward. Employees will be considered for a promotion if they perform very well and consistently from one year to another, have a strong learning agility, adapt to change, cope up with the challenge and deal with problems effectively. Also, they have passion to grow, feel engaged and optimistic about the future of the company. More importantly, they are honest and loyal to the company.

In the recent years, a lot of staff have grown their careers in Innotality. To name some,

លោក រ៉ី រ៉ូប៊ីតូ ពីបុគ្គលិកផ្នែកបដិសណ្ឋារកិច្ច ទៅជាប្រធានផ្នែកបដិសណ្ឋារកិច្ច។

Mr. Ry Roberto, from Senior Resident Host to Resident Host Manager.

លោកស្រី សួន រតនៈចំរើន ពីជំនួយការប្រធានផ្នែកគ្រប់គ្រងធនធានមនុស្ស ទៅជាប្រធានផ្នែកគ្រប់គ្រងធនធានមនុស្ស។

Ms. Soun Rattanak Chamroeun, from Assistant HR Manager to HR Manager.

and many more to name.

ការកសាងសមត្ថភាពរបស់បុគ្គលិកផ្នែកហិរញ្ញវត្ថុ

ថ្នាក់ដឹកនាំផ្នែកហិរញ្ញវត្ថុ ត្រូវបានលើកទឹកចិត្តក្នុងការបណ្តុះបណ្តាលសហការីផ្នែកហិរញ្ញវត្ថុទាំងអស់ ដើម្បីបង្កើនជំនាញបច្ចេកទេសដល់ពួកគាត់ ដោយមានជំនឿថាការបណ្តុះបណ្តាលជាបន្តបន្ទាប់ គឺជាមធ្យោបាយដើម្បីលើកទឹកចិត្តក្រុមការងារផង និងធ្វើឱ្យពួកគាត់អាចបង្កើនចំណេះដឹងបន្ថែមទៀត ក្នុងការអនុវត្តការងារប្រកបដោយប្រសិទ្ធិភាព និងប្រសិទ្ធិផលផង។

កិច្ចការភាគច្រើននៅក្នុងនាយកដ្ឋានហិរញ្ញវត្ថុ ត្រូវពឹងផ្អែកលើកម្មវិធី MS Excel។ ការយល់ដឹងពីបច្ចេកទេសក្នុងការប្រើប្រាស់កម្មវិធី MS Excel អាចជួយពន្លឿនការងារបានយ៉ាងមានប្រសិទ្ធភាព។ ដោយយល់ដូច្នេះហើយទើប លោក លី ម៉ েងផ្ចាត ដែលជាប្រធានផ្នែកត្រួតពិនិត្យហិរញ្ញវត្ថុ បានរៀបចំកាលវិភាគដើម្បីបណ្តុះបណ្តាលកម្មវិធីនេះ ដល់សហការីទាំងអស់គ្នា នៅនាយកដ្ឋានហិរញ្ញវត្ថុរបស់យើង។ បន្ទាប់ពីចំណាយពេលអស់ ២០ម៉ោង ដើម្បីរៀនកម្មវិធីនេះមក ក្រុមការងាររបស់យើងមានអារម្មណ៍ថា ពួកគាត់មានទំនុកចិត្តជាងមុនក្នុងការប្រើប្រាស់កម្មវិធី MS Excel។ នាយកដ្ឋានហិរញ្ញវត្ថុក៏មានបំណងដើម្បីរៀបចំវគ្គបណ្តុះបណ្តាល កម្មវិធីដែលពាក់ព័ន្ធដទៃទៀត ដល់ក្រុមការងាររបស់យើង នៅក្នុងខែបន្តបន្ទាប់ខាងមុខនេះផងដែរ។

CAPACITY BUILDING TRAINING IN FINANCE

Management team in Finance department is motivated to conduct training to all finance associates to improve their functional skills, since it's believed that ongoing training is a way to motivate the team and keep them constantly developed for more effective result and productivity.

Most of the tasks in Finance department are administered using MS Excel. Knowing techniques how to use Excel effectively can help speed up our works. Understanding this, Mr. Ly Mengphat, a Financial Controller, scheduled to facilitate this training with the participation from all of our Finance associates. After 20 hours spending on this program, our team feels more confident in using MS Excel. Finance department also aims to host other relevant programs for our team in the upcoming months.

ភ្ញៀវរៀនពីរបៀបបត់ផ្កាឈូក

ក្រុមការងារផ្នែកហិរញ្ញវត្ថុតែងតែចូលរួមចំ-ណែកក្នុងព្រឹត្តិការណ៍របស់ Innotality។ នៅក្នុងឱកាសនៃបុណ្យណូអែល និងចូលឆ្នាំសាកល ក្រុមការងារផ្នែកហិរញ្ញវត្ថុមានកិត្តិយសដែលបានចូលរួមសម្របសម្រួលនៅក្នុងសកម្មភាព "**បត់ផ្កាឈូក**"។ ជាមួយនឹងសកម្មភាពបែបនេះយើងបានទាក់ទាញភ្ញៀវជាច្រើនចូលរួមដកបទពិសោធ-ន៍ក្នុងការបត់ផ្កាឈូកតាមរបៀបផ្សេងៗគ្នា និងភ្លក់រសជាតិដ៏ផ្អែមដែលមិនអាចបំភ្លេចបានរបស់ផ្លែឈូកស្រស់។ សកម្មភាពបត់ផ្កាឈូក ក៏មានបង្ហាញជាញឹកញាប់រៀងរាល់សប្តាហ៍ នៅចំកណ្តាលបរិវេណទទួលភ្ញៀវនៃសណ្ឋាគារ Borei Angkor Resort & Spa ក្នុងគោលបំណងផ្សព្ព-ផ្សាយបន្ថែមនូវផ្កាឈូកខ្មែរ ដល់ភ្ញៀវទេសចរណ៍ទាំងអស់នៅជុំវិញពិភពលោក ដែលមកស្នាក់នៅក្នុងសណ្ឋាគាររបស់យើង។

GUESTS LEARN LOTUS FLOWER FOLDING

Finance team have always taken part in the events in Innotality. In the occasion of Christmas and New Year, finance team are honored to coordinate “**Lotus Flower Folding**”. With such activity we attract a lot of guests to join, learn new local experience of how to fold the different styles of lotus flower, and taste the freshlotus seed. Lotus flower folding activity is demonstrated at the heart of **Borei Angkor Resort & Spa**’s lobby every few days per week in the purpose of promoting Cambodian local flower to all guests who stay with us from all over the world.

សំណួរ និងចំលើយដើម្បីទទួលបានឱកាសឈ្នះរង្វាន់!!!

ឱកាសឈ្នះ រង្វាន់

សូមឆ្លើយសំណួរខាងក្រោមឱ្យបានត្រឹមត្រូវដើម្បីទទួលបានឱកាសឈ្នះរង្វាន់។

សំណួរទី១៖

ដើម្បីឱ្យក្រុមហ៊ុនសំរេចបានជោគជ័យតាមទស្សនៈវិស័យរបស់ខ្លួន ក្រុមហ៊ុនបានឱ្យតំលៃលើកត្តាប្រាំយ៉ាង ដែលនិយោជិតគ្រប់រូបត្រូវអនុវត្តតាម។ តើតំលៃស្នូលទាំងប្រាំនោះមានអ្វីខ្លះ?

ចូរជ្រើសរើសចំលើយដែលត្រឹមត្រូវដែលមានតែមួយគត់នៅខាងក្រោម រួចសរសេរចំលើយរបស់អ្នកនៅលើ កាតចំលើយ៖

ក. ភាពច្នៃប្រឌិត (Creaginality) ខ. វឌ្ឍនភាព (Progress) គ. កេរ្តិ៍តំណែល (Legacy)
ឃ. មុទិតា (Mudita) ង. មោទនភាព (Pride) ច. ក ខ គ ឃ និង ង ត្រូវទាំងអស់

សំណួរទី២៖

តើតំលៃស្នូលនីមួយៗមានអត្ថន័យដូចម្តេច? ចូរផ្គូរផ្គងតំលៃស្នូលនីមួយៗក្នុងជួរឈរ " ក " ជាមួយអត្ថន័យរបស់វានៅក្នុងជួរឈរ " ខ " ។

សូមសរសេរចំលើយរបស់អ្នកនៅលើ កាតចំលើយ៖

ជួរឈរ " ក "	ជួរឈរ " ខ "
ក. ភាពច្នៃប្រឌិត(Creaginality)	១. ការរៀនសូត្រ និងការច្នៃប្រឌិតថ្មីតែងតែមានដំណើររួមគ្នា។ ការមិនទទួលបានភាពជោគជ័យ គឺនៅពេលដែលអ្នកគិតថាអ្វីដែលអ្នកបានធ្វើកាលពីម្សិលមិញ វាគ្រប់គ្រាន់ហើយសំរាប់ថ្ងៃស្អែក។
ខ. វឌ្ឍនភាព (Progress)	២. គួររៀបចំខ្លួនឱ្យក្លាយជាមនុស្សដែលអាចសម្រេចភារកិច្ចប្រកបដោយគុណភាពខ្ពស់។ មានបុគ្គលមួយចំនួនមិនអាចសម្របខ្លួនឱ្យសមស្របនៅក្នុងបរិស្ថានមួយដែលតម្រូវឱ្យមានគុណភាពល្អឥតខ្ចោះបានឡើយ។
គ. កេរ្តិ៍តំណែល(Legacy)	៣. ប្រសិនបើអ្នកធ្វើការដើម្បីតែប្រាក់ អ្នកនឹងមិនអាចរកវាបានឡើយ ប៉ុន្តែប្រសិនបើអ្នកស្រលាញ់អ្វីដែលអ្នកកំពុងធ្វើ ហើយជានិច្ចកាលចាត់ទុកអតិថិជនជាធំ នោះភាពជោគជ័យនឹងក្លាយជារបស់អ្នកជាដរាប។
ឃ. មុទិតា(Mudita)	៤. ការរួបរួមគ្នា គឺជាការចាប់ផ្តើម ការចេះថែរក្សាគ្នាទៅវិញទៅមក គឺជាវឌ្ឍនភាព ហើយការសហការគ្នា គឺជាភាពជោគជ័យ។
ង. មោទនភាព(Pride)	៥. រាល់ពេលដែលអ្នកញញឹមដាក់នរណាម្នាក់ វាគឺជាទង្វើមួយនៃក្តីស្រលាញ់ជាវត្ថុអនុស្សាវរីយ៍សំរាប់បុគ្គលនោះ និងជារឿងមួយដ៏ប្រពៃបំផុត។

តើត្រូវធ្វើដូចម្តេចដើម្បីជ្រើសរើសរង្វាន់

- ☑ សូមបំពេញឈ្មោះ និងសរសេរចំលើយរបស់អ្នកនៅលើកាតចំលើយដែលផ្តល់ជូន
- ☑ សូមយកកាតចំលើយរបស់អ្នកទៅដាក់ក្នុងធុងឆ្នោត នៅការិយាល័យធនធានមនុស្សឱ្យបានមុនថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៦
- ☑ មានតែអ្នកដែលឆ្លើយត្រូវទាំងពីរសំណួរប៉ុណ្ណោះ ទើបមានឱកាសឈ្នះរង្វាន់
- ☑ ការចាប់និងប្រកាស់ឈ្មោះអ្នកឈ្នះរង្វាន់ចំនួន ១០ រង្វាន់នឹងត្រូវធ្វើឡើងនៅថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៦ ដោយផ្នែកធនធានមនុស្ស

www.innotality.com

A: National Road 6, Banteay Chas, Siem Reap, Cambodia | T: +855 63 969 300 | F: +855 63 969 301 | E: info@innotality.com